ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលដីកា

សមាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៧១

ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨

នាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

សាលដីកា

លេខ ៦៤"VI"

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥- លោក [redacted] ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៤២ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៨ របស់ឈ្មោះ [redacted] សំអន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០២ ក្រV "វ" ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ដែលមានៈ

-ជនជាប់ចោទឈ្មោះ [redacted] សំអន ភេទស្រី អាយុ៦៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅ [redacted] ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "វ" ប្តីឈ្មោះ [redacted] មានកូន ០៩នាក់ ទោសពីមុនគ្មាន។ (ដើមបណ្តឹងសាទុក្ខ)

-មានមេធាវីការពារ លោក [redacted] ស្រ៊ីវ



Scanned with CamScanner

**ជាប់ចោទពីបទ:** ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែមីនា ដល់ខែឧសភា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ៥D ផ្លូវវត្តចាស់ ក្រុម៥ ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**អំពីអង្គហេតុ**

កាលពីអំឡុងខែមីនា ដល់ខែឧសភា ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ ឈ្មោះ [redacted] សំអន និងឈ្មោះ [redacted] ដេវីត បានធានាអះអាងថានឹងជួយសម្រួលបែបបទដើម្បីឱ្យបងប្អូនរបស់ឈ្មោះ [redacted] សៀងលី ចំនួន០៧នាក់ទៅរស់នៅសហរដ្ឋអាមេរិក។ ដោយភាគីឈ្មោះ [redacted] សៀងលី និងឈ្មោះ [redacted] សំអន បានធ្វើកិច្ចព្រមព្រៀងទទួល និងប្រគល់ប្រាក់ជាបន្តបន្ទាប់រហូតអស់ទឹកប្រាក់ចំនួន១៩៦០០$។ បន្ទាប់ពីបានទទួលប្រាក់ហើយឈ្មោះ [redacted] សំអន បានធានាអះអាងថាជាច្រើនលើកថា នឹងរត់ឯកសារយកបងប្អូនរបស់ឈ្មោះ [redacted] សៀងលី ទៅរស់នៅសហរដ្ឋអាមេរិកតាមការកំណត់ តែរហូតមកដល់សព្វថ្ងៃនេះឈ្មោះ [redacted] សំអន និងឈ្មោះ [redacted] ដេវីត មិនបានរត់បែបបទអ្វីទាំងអស់ ហើយមិនព្រមប្រគល់ប្រាប់មកឈ្មោះ [redacted] សៀងលី ឡើយ ដោយគេចវេសធ្វើឱ្យឈ្មោះ [redacted] សៀងលី ខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤២៩ (ណ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] សំអន ភេទស្រី អាយុ៦៦ឆ្នាំ ជាតិខ្មែរ សំរេចដាក់ពន្ធនាគារកំណត់ចំនួន១ឆ្នាំ តែទោសនេះត្រូវព្យួរ ពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែមីនា ដល់ខែឧសភា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] សំអន សងប្រាក់ចំនួន១៩៦០០$ និងប្រាក់ជម្ងឺចិត្តចំនួន ៤.000.000 រៀលឱ្យទៅឈ្មោះ [redacted] សៀងលី ការទាមទារលើសពីនេះបដិសេធចោល។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សំអន និងមេធាវីការពារឱ្យជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សៀងលី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២៣០ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] សំអន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤២៩ "ណ" ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ០២ ក្រV "វ" ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤២៩ (ណ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ បើកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខ តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៤២ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] សំអន បានប្តឹងមិនសុខចិត្តនិងសាលដីកាព្រហ្មទណ្ឌលេខ ០២ ក្រV "វ" ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា ថ្វីត្បិតតែជនជាប់ចោទបានសារភាពខ្លះ និងបដិសេធខ្លះលើអង្គហេតុនៃការចុះកិច្ចសន្យារត់ការដើម្បីរបានទៅរស់នៅប្រទេសអាមេរិក ក៏ប៉ុន្តែការរត់ការក្នុងលក្ខណៈចុះមករៀបការដើម្បីបានទៅរស់នៅអាមេរិកនោះ គឺមានភាពស្មុគស្មាញដែលគប្បីសាកសួរបន្ថែមឱ្យបានច្បាស់ពីតម្រុយនៃចេតនាទុច្ចរិតរបស់ជនជាប់ចោទ ក្នុងការបន្លំយកប្រាក់ពីជនរងគ្រោះ។ ជាងនេះទៅទៀត ការរត់ការនេះអាចជាការរត់ការលើអាពាហ៍ពិពាហ៍ក្លែងក្លាយ ឬខុសច្បាប់ដើម្បីបានទៅរស់នៅអាមេរិកតែប៉ុណ្ណោះ ជាការបង្កើតកិច្ចសន្យាដោយខុសច្បាប់ ឬយ៉ាងណា។ ធ្វើការសាកសួរបន្ថែម ទៅលើសំណុំរឿងព្រហ្មទណ្ឌលេខ០២ ក្រV "វ" ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍។

-ក្រឡាបញ្ជីអានសារណាការពារចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សៀងលី បានឆ្លើយថា ខ្លួនពិតជាមានការប្តឹងទាមទារប្រាក់សំណង និងជម្ងឺចិត្តក្នុងអង្គហេតុរឿងក្តីនេះទៅតុលាការព្រហ្មទណ្ឌផង និងទៅតុលាការរដ្ឋប្បវេណីផង។ បច្ចុប្បន្នសំណុំរឿងក្តីរដ្ឋប្បវេណីក៏មកដល់តុលាការកំពូលដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានសារណាការពាររបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពិបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ
## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៤២ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ , ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៤២ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែខុសនឹងគតិច្បាប់ ។

៣-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សំអន បានទទួលមរណភាពកាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ដូចមានបញ្ជាក់ក្នុងសេចក្តីចម្លងសំបុត្រមរណភាពលេខ ៤២ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ សៀវ ភៅមរណភាពលេខ ០២/២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ឬស្សីកែវ។ ហេតុដូច្នេះ តុលាការ កំពូលគប្បីសម្រេចរំលត់បណ្តឹងអាជ្ញាលើជនជាប់ចោទឈ្មោះ [redacted] សំអន យោងតាមបទប្បញ្ញត្តិមាត្រា៧ ត្រង់ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-យល់ឃើញថា តាមសារណាការពារចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន បានលើកឡើងនូវអំណះអំណាងថា ដើមបណ្តឹងរដ្ឋប្បវេណីក៏បានប្តឹងទាមទារប្រាក់ដដែលនេះ និងជំងឺចិត្ត ក្នុងអង្គហេតុដដែលនេះទៅតុលាការរដ្ឋប្បវេណីផងដែរ ហើយតុលាការរដ្ឋប្បវេណីក៏កំពុងតែចាត់ការលើបណ្តឹង រដ្ឋប្បវេណីរបស់គាត់ផងដែរ។ រីឯភាគីដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយនៅចំពោះមុខអង្គសវនាការរបស់តុលាការ កំពូលថា ខ្លួនពិតជាមានការប្តឹងទាមទារប្រាក់សំណង និងជំងឺចិត្តក្នុងអង្គហេតុរឿងក្តីនេះទៅតុលាការព្រហ្មទណ្ឌ ផង និងទៅតុលាការរដ្ឋប្បវេណីផងដែរ។ បច្ចុប្បន្នសំណុំរឿងក្តីរដ្ឋប្បវេណីក៏បានមកដល់តុលាការកំពូល ដែល តុលាការកំពូលក៏កំពុងតែរង់ចាំសំណុំរឿងព្រហ្មទណ្ឌនេះត្រូវបានចាត់ការជម្រះចប់សព្វគ្រប់ដែរនោះ តុលាការ កំពូលយល់ថា សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញលេខ ៤២៩ “ណ” ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៦ ដែលបានប្រកាសពិរុទ្ធភាព សម្រេចអំពីទោស និងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] សំអន និង បង្គាប់ឱ្យឈ្មោះ [redacted] សំអន សងសំណងអន្តរាយ និងជំងឺចិត្តទៅឱ្យឈ្មោះ [redacted] សៀងលី ហើយសាលក្រមនេះ ត្រូវ បានឧទ្ធរណ៍ភ្នំពេញសម្រេចតម្កល់ទាំងមូល តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ០២ ក្រV “វ” ចុះថ្ងៃទី១៩ ខែ មករា ឆ្នាំ២០១៨ គឺត្រឹមត្រូវហើយ ដោយហេតុថា អំពើដែលជនជាប់ចោទឈ្មោះ [redacted] សំអន បានប្រព្រឹត្តក្នុង អង្គហេតុបានលើកឡើងក្នុងសំណុំរឿងក្តីនេះនោះ មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសឆបោក ។ ដោយអនុវត្តតាម បទប្បញ្ញត្តិមាត្រា ២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចសម្រេចតម្កល់នូវផ្នែកសេចក្តីសម្រេចអំពី សំណងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌនេះបាន។



Scanned with CamScanner

៥-យល់ឃើញថា សាលដីកាព្រហ្មណ្ឌលេខ ០២ ក្រV “វ” ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។ ប៉ុន្តែដោយសារតែជនជាប់ចោទ ឈ្មោះ [redacted] សំអន បានទទួលមរណភាពនៅក្នុងដំណាក់កាលនីតិវិធីចាត់ការរឿងក្តីនៅដំណាក់កាលចំណាត់ការ លើរឿងក្តីរបស់តុលាការកំពូលនោះ តុលាការកំពូលគប្បីសម្រេចកែប្រែលើសេចក្តីសម្រេចរបស់តុលាការ អង្គហេតុនូវចំណុចដែលពាក់ព័ន្ធនឹងការផ្តន្ទាទោសលើខ្មោចឈ្មោះ [redacted] សំអន ដែលនឹងត្រូវរំលត់បណ្តឹងអាជ្ញា ។

## ហេតុដូច្នេះ
## សម្រេចសេចក្តី

១-បដិសេធ បណ្តឹងសាទុក្ខលេខ ៣៤២ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សំអន ។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ០២ ក្រV “វ” ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។ លើកលែងតែចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤២៩ “ណ” ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញដែលបានសម្រេច និងប្រកាសទោសលើជនជាប់ ចោទឈ្មោះ [redacted] សំអន ត្រូវកែប្រែមកជា *“រំលត់បណ្តឹងអាជ្ញាលើខ្មោចឈ្មោះ ម៉ក់ សំអន ”* វិញ។

៣-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃសុក្រ ទី០៦ ខែមីនា ឆ្នាំ២០២០ និងប្រកាសនាជាសាធារណៈនៅថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner